# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ៨៥ "ក្រ១១" ឃ១

ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ៣០៦៧

ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២

-សំណុំរឿងស៊ើបសួរលេខ២៣៨៧

ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២

-សំណុំរឿងជំនុំជម្រះលេខ៤០៦២

ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក នៅសាលសវនាការទី៣ ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

-លោក [redacted] ជាចៅក្រុមប្រឹក្សា

-លោក [redacted] ជាចៅក្រុមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣០៦៧ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **ចំរើន** ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរសិស្ស មានទីកន្លែងកំណើតនៅ [redacted] ខេត្តស្វាយរៀង ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ភូមិថ្មគោល សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុផល "រស់"ម្តាយឈ្មោះ សា ម៉ន"រស់"នៅលីវ ជាអនីតិជន ទោសពីមុន គ្មាន។

-ឃុំខ្លួនក្នុងពន្ធនាគាររាជធានីភ្នំពេញ"PJ" តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥១៧១ "ឈ១" ដ.ឃ.ដ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

២-ឈ្មោះ [redacted] **តុលា** ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបររៀនជាងឡាន មានទីកន្លែងកំណើតនៅ [redacted] ខេត្តកំពត ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ភូមិត្រពាំងថ្លឹង៣ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] រ៉ា"រស់"ម្តាយឈ្មោះ [redacted] ស្រីអូន "រស់"នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។

-ឃុំខ្លួនក្នុងពន្ធនាគាររាជធានីភ្នំពេញ "PJ" តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥១៧០ "ឈ១" ដ.ឃ.ដ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។



Scanned with CamScanner

-ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវបេតុង វត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ និងនៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងបទ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខបុរីហុងឡាយ ផ្លូវវេងស្រេង ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ឈ្មោះ [redacted] **ម៉េងឡុង** ហៅ **រ៉ុង** ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរសិស្ស ទីកន្លែងកំណើត[redacted]ខេត្តកំពង់ចាម ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ភូមិថ្មគោល សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] លុច "រស់" ម្តាយឈ្មោះ [redacted] ង៉ឹម "រស់" នៅលីវ ជាអនីតិជន ទោសពីមុន គ្មាន។

-ឃុំខ្លួនក្នុងពន្ធនាគាររាជធានីភ្នំពេញ"PJ" តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥១៦៧ "ឈ១" ដ.ឃ.ដ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

៤-ឈ្មោះ [redacted] **សុខហេង** ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរសិស្ស មានទីកន្លែងកំណើតនៅ [redacted] ខេត្តព្រៃវែង ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅភូមិថ្មគោល២ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ដារ៉ា"រស់" ម្តាយឈ្មោះ [redacted] ស៊ីវៀន "រស់" នៅលីវ ជាអនីតិជន ទោសពីមុន គ្មាន។

-ឃុំខ្លួនក្នុងពន្ធនាគាររាជធានីភ្នំពេញ "PJ" តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥១៦៩ "ឈ១" ដ.ឃ.ឃ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

៥-ឈ្មោះ [redacted] **ហេងលាប** ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរសិស្ស មានទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តស្វាយរៀង ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅសង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] វណ្ណា "រស់" ម្តាយឈ្មោះ [redacted] សុគន្ធ "រស់" នៅលីវ ជាអនីតិជន ទោសពីមុន គ្មាន។

-ឃុំខ្លួនក្នុងពន្ធនាគាររាជធានីភ្នំពេញ "PJ" តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥១៦៨ "ឈ១" ដ.ឃ.ឃ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវបេតុង វត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍-សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ និងនៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣, មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យ



Scanned with CamScanner

គ្រឿងញៀន។

-មានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុខហេង**, ជនជាប់ចោទឈ្មោះ [redacted] **ម៉េងឡុង** ហៅ **រ៉ុង**, ជនជាប់ចោទឈ្មោះ [redacted] **ចំរើន** និងជនជាប់ចោទឈ្មោះ [redacted] **ហេងលាភ** មានការិយាល័យស្ថិតនៅផ្ទះលេខ៥ ផ្លូវលេខ៥ ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **តុលា** មានការិយាល័យស្ថិតនៅអគារលេខ១០៧៥ ផ្លូវលេខ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

## អង្គហេតុនៃរឿងមានដូចតទៅ៖

កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ កម្លាំងសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលចោមចៅទី១ បានជិះម៉ូតូល្បាតការពារក្នុងភូមិសាស្ត្រ មកដល់ចំណុចមុខបុរីហុងឡាយ ផ្លូវវេងស្រេង ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ក៏បានជួប ១.ឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ១៥ឆ្នាំ ២.ឈ្មោះ [redacted] ម៉េងឡុង ភេទប្រុស អាយុ១៦ឆ្នាំ, ៣.ឈ្មោះ [redacted] តុលា ភេទប្រុស អាយុ១៧ឆ្នាំ ,៤.ឈ្មោះ [redacted] សុខហេង ភេទប្រុស អាយុ១៥ឆ្នាំ និង ៥.ឈ្មោះ [redacted] ហេងលាប ភេទប្រុស អាយុ១៤ឆ្នាំ ដោយកម្លាំងសមត្ថកិច្ចជំនាញធ្វើការឆែកឆេរលើក្រុមជនខាងលើបានរកឃើញវត្ថុតាងរួមមាន ក្រាមពណ៌សថ្លា ចំនួន ០២កញ្ចប់តូច លើឈ្មោះ [redacted] ចំរើន និងថ្នាំគ្រាប់ ពណ៌ស្វិកឈើ(ខៀវខ្ចី) ចំនួន ០២គ្រាប់ លើឈ្មោះ [redacted] តុលា រួចកម្លាំងសមត្ថកិច្ចបានដកហូតវត្ថុតាងខាងលើ ដើម្បីនាំយកមកសាកសួរតាមនីតិវិធីច្បាប់។

ក្រៅពីសកម្មភាពខាងលើក្រុមជនជាប់ចោទក៏បានឆ្លើយសារភាពថា កន្លងមកពួកខ្លួនធ្លាប់បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃចំនួន ០២លើកទៀត ដោយលើកទី១ ធ្វើសកម្មភាពឆក់នៅតាមបណ្តោយផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ តែមិនបានសម្រេច និងលើកទី២ បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃចំនួន ០១ គ្រឿង ម៉ាក OPPO ពីជនរងគ្រោះ ភេទប្រុស ជិះម៉ូតូម៉ាក HONGDA SCOPY-I ពណ៌ខ្មៅ នៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ បានសម្រេច រួចយកទូរស័ព្ទនោះទៅលក់នៅហាងទិញ លក់ និងបញ្ចាំទូរស័ព្ទដៃ ហាងម៉ែអាតាយ ស្ថិតនៅលើផ្លូវវេងស្រេង ក្បែរផ្សារកាណាឌីយ៉ាស៊ី បានប្រាក់ចំនួន ៩០ $ ចែកគ្នាស៊ីចាយអស់។

-**បានឃើញ** របាយការណ៍សំយោគលេខ**១៣៧/០២២ រ.ប.ក** ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **២៣៩៧ អ.យ.ធ** ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **៣៩១៧ អ.យ.ធ** ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ **៥៤២៧ "ឈ១"** ៨៨ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២



Scanned with CamScanner

របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសមនាគារ

-ជនជាប់ចោទឈ្មោះ [redacted] ម៉េងឡុង ហៅ រ៉ុង បានឆ្លើយថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០២ និង ០០ នាទី យប់រំលងអធ្រាតរូបខ្លួន និងបក្ខពួកចំនួន០៤នាក់ទៀត ឈ្មោះ[redacted] ចំរើន ហៅ អារើន ភេទប្រុស, ឈ្មោះ[redacted] តុលា ហៅ តុលា ភេទប្រុស, ឈ្មោះ[redacted] សុខហេង ហៅវ៉ា, ឈ្មោះ[redacted] ហេងលាប ហៅកៃ ភេទប្រុស កំពុងនាំគ្នាឈប់ម៉ូតូចំនួន ០២ គ្រឿង អង្គុយលេងនៅខាងមុខបុរីហុងឡាយ ផ្លូវចោមចៅ ហៅផ្លូវវេងស្រេង ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ភ្លាមនោះស្រាប់តែមានកម្លាំងសមត្ថកិច្ចនគរបាលជិះម៉ូតូល្បាតមកដល់ហើយបានធ្វើការត្រួតពិនិត្យនិងឆែកឆេរលើខ្លួនប្រាណរកឃើញ ក្រាមពណ៌សថ្លា ចំនួន ០១កញ្ចប់ថង់តូច នៅលើខ្លួនឈ្មោះ [redacted] ចំរើន ហៅអារើន ចំណែកក្រាមពណ៌សថ្លា ចំនួន០១កញ្ចប់ថង់តូច និងថ្នាំគ្រាប់ពណ៌ស្វ៊ាយឈើ(ខៀវខ្ចី) ចំនួន០២គ្រាប់ទៀត នៅលើខ្លួនឈ្មោះ [redacted] តុលា ហើយរូបខ្លួន និងបក្ខពួក បានឆ្លើយសារភាពថាពួកខ្លួនធ្លាប់ធ្វើសកម្មភាពឆក់ទូរស័ព្ទ និងកាបូបនៅតាមផ្លូវសាធារណៈកន្លងមក ទើបកម្លាំងសមត្ថកិច្ចនគរបាលបានឃាត់រូបខ្លួន និងបក្ខពួកចំនួន ០៤នាក់ ទៀត, ឈ្មោះ[redacted] ចំរើន ហៅ អារើន ភេទប្រុស, ឈ្មោះ[redacted] តុលា ហៅតុលា ភេទប្រុស, ឈ្មោះ [redacted] សុខហេង ហៅវ៉ា ភេទប្រុស, ឈ្មោះ [redacted] ហេងលាប ហៅកៃ ភេទប្រុស រួមនិងវត្ថុតាងនាំយកមកសាកសួរនៅផ្នែកនគរបាលយុត្តិធម៌នៃអធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យតែម្តង ។ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០៥ និង ៤០ នាទីទៀបភ្លឺ រូបខ្លួនបក្ខពួកចំនួន ០៤ នាក់ទៀត ឈ្មោះ[redacted] ចំរើន ហៅអារើន, ឈ្មោះ[redacted] តុលា ហៅតុលា ភេទ ប្រុស, ឈ្មោះ[redacted] សុខហេង ហៅ វ៉ា, ឈ្មោះ[redacted] ហេងលាប ហៅកៃ បាននាំគ្នាចេញពីដេកនៅផ្ទះសំណាក់នាគទេព សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ ដោយខ្លួនបានជិះម៉ូតូ ០១ គ្រឿង ម៉ាកហុងដាឌ្រីម C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៣ គ្មានផ្លាកលេខ ដឹកឈ្មោះ[redacted] ចំរើន ហៅ អារើន និងឈ្មោះ[redacted] សុខហេង ហៅ វ៉ា ចំណែកឈ្មោះ[redacted] តុលា ហៅតុលា បានជិះម៉ូតូ០១គ្រឿងម៉ាកហុងដាឌ្រីម C125 ពណ៌ក្រហម ស៊េរីឆ្នាំ២០២២ ពាក់ផ្លាកលេខភ្នំពេញ1JM-8711 ដឹកឈ្មោះ[redacted] ហេងលាប ហៅកៃ ទៅតាមផ្លូវបេតុង ខាងកើតវត្តអង្គតាម៉ិញភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ ក៏ឃើញជនរងគ្រោះជាមនុស្សស្រី កំពុងតែដើរតាមផ្លូវតែម្នាក់ឯង ក្នុងដៃកាន់ទូរស័ព្ទ ដៃ០១គ្រឿងនិយាយ ស្រាប់តែឈ្មោះ[redacted] ហេងលាប ហៅកៃ បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីជនរងគ្រោះ ប៉ុន្តែពុំបានសម្រេច ទើបពួកខ្លួនបាននាំគ្នាជិះម៉ូតូរត់គេចខ្លួន។ រហូតមកដល់ប្រហែល ១៨ និង ១៥នាទី ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ រូបខ្លួនបានជិះម៉ូតូ០១ គ្រឿងម៉ាក ហុងដាឌ្រីម C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៣ គ្មានផ្លាកលេខ ដឹកឈ្មោះ [redacted] ចំរើន ហៅអារើន ចំណែក ឈ្មោះ[redacted] តុលា ហៅតុលា បានជិះម៉ូតូ០១គ្រឿងម៉ាកហុងដាឌ្រីម C125 ពណ៌ក្រហម ស៊េរីឆ្នាំ ២០២២ ពាក់ផ្លាកលេខភ្នំពេញ 1JM-8711 ដឹកឈ្មោះ [redacted] ហេងលាប ហៅកៃ និងឈ្មោះ [redacted] សុខហេង ចេញពីខាងមុខក្លឹបមីតណាយ ទៅដល់ភ្លើងស្តុបទួលពង្រ ក៏ឃើញជនរងគ្រោះ ភេទប្រុស ជិះម៉ូតូ០១គ្រឿង ម៉ាកហុងដាស្កុបពីពណ៌ខ្មៅ មិនចាំស៊េរី និងផ្លាកលេខ ជិះតែម្នាក់ឯងបានដាក់ទូរស័ព្ទដៃ ០១គ្រឿង នៅក្នុងហោប៉ៅខាងមុខ ទើបពួកខ្លួនជិះដេញតាមរហូតមកដល់ចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់-ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រូបខ្លួនក៏ជិះម៉ូតូដឹកឈ្មោះ [redacted] ចំរើន ហៅអារើន ទៅក្បែរម៉ូតូរបស់

ជនរងគ្រោះ រួចឈ្មោះ [redacted] ចំរើន ហៅអារើន បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃ ពីជនរងគ្រោះបានសម្រេចហើយ រូបខ្លួន និងបក្ខពួក បាននាំគ្នាជិះម៉ូតូគេចខ្លួន ចេញពីកន្លែងកើតហេតុដោយឃើញជនរងគ្រោះជិះម៉ូតូដេញតាមដែរតែត្រូវ បក្ខពួក ដែលជិះម៉ូតូចាំបិទគូថបានជិះម៉ូតូបិទផ្លូវមិនឱ្យជិះម៉ូតូដេញតាម ដោយរូបខ្លួន និងឈ្មោះ [redacted] ចំរើន ហៅអារើន បាននាំគ្នាយកទូរស័ព្ទដៃ ០១ គ្រឿងម៉ាក OPPO ដែលឆក់បាននោះទៅលក់ នៅហាង ទិញលក់និងបញ្ចាំទូរស័ព្ទដៃនៅហាងម៉ែអាតាយ ផ្លូវចោមចៅ ហៅ ផ្លូវវែងស្រេង ជិតផ្សារកាណាស៊ីធីបានប្រាក់ចំនួន ៩០$ (កៅសិបដុល្លារអាមេរិក) ហើយខ្លួនបានលុយចំនួន ៨០.០០០៛ (ប្រាំបីម៉ឺនរៀល) រួចហើយក៏បែកផ្លូវ ។ រយៈកាលកន្លងមករូបខ្លួនពុំធ្លាប់ជាប់ពន្ធនាគារនោះទេ ចំណែកគ្រឿងញៀន គឺខ្លួនចេះជក់ ហើយរូបខ្លួន និងបក្ខពួកខាងលើធ្លាប់ធ្វើសកម្មភាពជិះម៉ូតូឆក់ទូរស័ព្ទដៃ និងកាបូបតាមផ្លូវសាធារណជាច្រើនកន្លែងតែពុំបានសម្រេច ។ ខ្លួនបានដឹង និងសារភាពពីទោសកំហុសដែលបានប្រព្រឹត្តនេះហើយ ខ្លួនសំណូមឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

-ជនជនជាប់ចោទឈ្មោះ [redacted] ចំរើន បានឆ្លើយសារភាពថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង០២និង០០នាទីយប់រំលងអធ្រាត រូបខ្លួន និងបក្ខពួកចំនួន០៤នាក់ទៀត ,ឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង ឈ្មោះ [redacted] តុលា ហៅតុលា ,ឈ្មោះ [redacted] សុខហេង ហៅ រ៉ាំ,ឈ្មោះ [redacted] ហេងលាប ហៅ កៃ កំពុងនាំគ្នាឈប់ម៉ូតូចំនួន០២គ្រឿងអង្គុយលេងនៅខាងមុខបុរីហុងឡាយ ផ្លូវចោមចៅ ហៅផ្លូវវែងស្រេង ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីចាំលក់គ្រឿងញៀន ភ្លាមនោះស្រាប់តែមានកម្លាំងសមត្ថកិច្ចនគរបាលជិះម៉ូតូល្បាតមកដល់ហើយបានធ្វើការត្រួតពិនិត្យ និងឆែកឆេរលើខ្លួនប្រាណ រកឃើញក្រាមពណ៌សថ្លាចំនួន ០១ កញ្ចប់ចង់តូច នៅលើខ្លួនប្រាណរបស់ខ្លួន ទុកលក់ឱ្យគេចំណែក ក្រាមពណ៌សថ្លាចំនួន ០១ កញ្ចប់ចង់តូច និងថ្នាំគ្រាប់ពណ៌ស្វាយឈើ(ខៀវខ្ចី) ចំនួន ០២ គ្រាប់ ទៀត នៅលើខ្លួនឈ្មោះ [redacted] តុលា ហើយរូបខ្លួន និងបក្ខពួក បានឆ្លើយសារភាពថាពួកខ្លួនធ្លាប់ធ្វើសកម្មភាពឆក់ទូរស័ព្ទដៃ និងកាបូបនៅតាមផ្លូវសាធារណៈកន្លងមក ទើបកម្លាំងសមត្ថកិច្ចនគរបាលបានឃាត់រូបខ្លួននិងបក្ខពួកចំនួន០៤នាក់ទៀត ឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង, ឈ្មោះ [redacted] តុលា ហៅតុលា, ឈ្មោះ [redacted] សុខហេង ហៅរ៉ាំ, ឈ្មោះ [redacted] ហេងលាប ហៅកៃ រួមនិងវត្ថុតាង នាំយកមកសាកសួរនៅផ្នែកនគរបាលយុត្តិធម៌ នៃអធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យតែម្តង។ ហើយកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង២០ និង០០ នាទី ឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង ជិះម៉ូតូ០១គ្រឿងម៉ាកហុងដាឌ្រីម C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៣ គ្មានផ្លាកលេខ ដឹករូបខ្លួនចំណែក ឈ្មោះ [redacted] តុលា ហៅតុលា បានជិះម៉ូតូ០១គ្រឿងម៉ាកហុងដាឌ្រីម C125 ពណ៌ក្រហម ស៊េរីឆ្នាំ២០២២ ពាក់ផ្លាកលេខភ្នំពេញ 1JM-8711 ដឹកឈ្មោះ [redacted] ហេងលាប ហៅកៃ និងឈ្មោះ [redacted] សុខហេង ហៅ រ៉ាំ ដឹកគ្នាចេញទៅដើររកធ្វើសកម្មភាពឆក់រហូតមកដល់ចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍-សែនជ័យ ក៏ឃើញជនរងគ្រោះ ភេទប្រុស ជិះម៉ូតូ ០១ គ្រឿងម៉ាកហុងដា ស្កុបពីពណ៌ខ្មៅ មិនចាំស៊េរី និងផ្លាកលេខជិះតែម្នាក់ឯង បានដាក់ទូរស័ព្ទដៃ០១គ្រឿង នៅក្នុងហោប៉ៅអាវខាងមុខ ឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង ក៏ជិះម៉ូតូដឹករូបខ្លួនទៅកៀកនិងម៉ូតូរបស់ជនរងគ្រោះ រួចឈ្មោះ [redacted] ចំរើន ហៅអារើន បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃពីជនរងគ្រោះបានសម្រេច ហើយរូបខ្លួន និងបក្ខពួក បាននាំគ្នាជិះម៉ូតូគេចខ្លួនចេញពីកន្លែងកើតហេតុដោយ ឃើញជនរងគ្រោះជិះម៉ូតូដេញតាមដែរ តែត្រូវបក្ខពួក ដែលជិះម៉ូតូចាំបិទគូថបានជិះម៉ូតូបិទផ្លូវមិនឱ្យជិះម៉ូតូដេញតាមខ្លួន និងឈ្មោះ [redacted]

ម៉េងឡុង ហៅរ៉ុង បាននាំគ្នាយកទូរស័ព្ទដៃ០១គ្រឿងម៉ាកOPPO ដែលឆក់បាននោះទៅលក់នៅហាងទិញលក់ និងបញ្ចាំទូរស័ព្ទដៃ នៅហាងម៉ែអាតាយ ផ្លូវចោមចៅ ហៅផ្លូវវែងស្រេង ជិតផ្សារកាណាស៊ីធីបានលុយ ចំនួន៥០$ (ហាសិបដុល្លារអាមេរិក) ហើយខ្លួនបានលុយចំនួន ១០០.០០០ (ដប់ម៉ឺនរៀល) រួចហើយក៏បែកផ្លូវរយៈកាលកន្លងមក រូបខ្លួនពុំធ្លាប់ជាប់ពន្ធនាគារនោះទេ ចំណែកគ្រឿងញៀនគឺខ្លួនចេះជក់ ។ ចំពោះរឿងខាងលើនេះ ខ្លួនបានដឹងពីទោសកំហុសហើយ និងសូមឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

-ជនជាប់ចោទចោទឈ្មោះ [redacted] តុលា បានឆ្លើយថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០២ និង ០០ នាទី យប់រំលងអាធ្រាត រូបខ្លួន និងបក្ខពួកចំនួន០៤នាក់ទៀត ,ឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង,ឈ្មោះ [redacted] ចំរើន ហៅ អារើន,ឈ្មោះ [redacted] ហេងលាប ហៅ កៃ ,ឈ្មោះ [redacted] សុខហេង ហៅវ៉ា កំពុងនាំគ្នាឈប់ម៉ូតូចំនួន០២គ្រឿង អង្គុយលេងនៅខាងមុខបុរីហុងឡាយ ផ្លូវចោមចៅ ហៅផ្លូវវែងស្រេង ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ភ្លាមនោះស្រាប់តែមានកម្លាំងសមត្ថកិច្ចនគរបាលជិះម៉ូតូល្បាតមកដល់ ហើយបានធ្វើការត្រួតពិនិត្យ និងឆែកឆេរលើ ខ្លួនប្រាណរកឃើញក្រាមពណ៌សថ្លា ចំនួន ០១ កញ្ចប់ថង់តូច និងថ្នាំគ្រាប់ពណ៌ស្លឹកឈើ (ខៀវខ្ចី)ចំនួន០២គ្រាប់ទៀត នៅលើរូបខ្លួនចំណែកក្រាមពណ៌សថ្លាចំនួន ០១កញ្ចប់ថង់តូច នៅលើខ្លួនប្រាណរបស់ឈ្មោះ [redacted] ចំរើន ហៅអារើន ទុកលក់ឱ្យគេហើយរូបខ្លួន និងបក្ខពួក បានឆ្លើយសារភាពថាពួក ខ្លួនធ្លាប់ធ្វើសកម្មភាពឆក់ទូរស័ព្ទដៃ និងកាបូបនៅតាមផ្លូវសាធារណៈកន្លងមក ទើបកម្លាំងសមត្ថកិច្ចនគរបាលបានឃាត់រូបខ្លួន និងបក្ខពួក ចំនួន ០៤ នាក់ទៀត ,ឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង ,ឈ្មោះ [redacted] ចំរើន ហៅ អារើន,ឈ្មោះ [redacted] តុលា ហៅតុលា ,ឈ្មោះ [redacted] សុខហេង ហៅវ៉ា រួមនិងវត្ថុតាង នាំយកមកសាកសួរនៅផ្នែកនគរបាលយុត្តិធម៌នៃអធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យតែម្តង ។ ហើយកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង២០ និង ០០ នាទី ឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង ជិះម៉ូតូ០១គ្រឿងម៉ាក ហុងដាឌ្រីម C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៣ គ្មានផ្លាកលេខដឹកឈ្មោះ [redacted] ចំរើន ហៅ អារើន ចំណែក ឈ្មោះ [redacted] តុលា ហៅតុលា បានជិះម៉ូតូ០១គ្រឿងម៉ាកហុងដាឌ្រីម C125 ពណ៌ក្រហម ស៊េរីឆ្នាំ២០២២ ពាក់ផ្លាកលេខភ្នំពេញ1JM-8711 ដឹករូបខ្លួន និងឈ្មោះ [redacted] សុខហេង ហៅ វ៉ា ដឹកគ្នាចេញទៅដើររកធ្វើសកម្មភាពឆក់ រហូតមកដល់ចំណុចផ្លូវ ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ ក៏ឃើញជនរងគ្រោះភេទប្រុស ជិះម៉ូតូ០១គ្រឿងម៉ាក ហុងដាស្កុបពីពណ៌ខ្មៅ មិនចាំស៊េរី និងផ្លាកលេខជិះតែម្នាក់ឯងបានដាក់ទូរស័ព្ទដៃ ០១គ្រឿង នៅក្នុងហោប៉ៅអាវខាងមុខឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង ក៏ជិះម៉ូតូដឹករូបខ្លួនទៅក្បែរនិងម៉ូតូរបស់ជនរងគ្រោះ រួចឈ្មោះ [redacted] ចំរើន ហៅអារើន បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃពីជនរងគ្រោះ បានសម្រេចហើយរូបខ្លួន និងបក្ខពួក បាននាំគ្នាជិះម៉ូតូគេចខ្លួន ចេញពីកន្លែងកើតហេតុដោយឈ្មោះ [redacted] ចំរើន ហៅអារើន និងឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង បាននាំគ្នាយកទូរស័ព្ទដៃ០១គ្រឿងម៉ាកOPPO ដែលឆក់បាននោះ ទៅលក់នៅហាងទិញ លក់ និងបញ្ចាំ ទូរស័ព្ទដៃនៅហាងម៉ែអាតាយ ផ្លូវចោមចៅហៅ ផ្លូវវែងស្រេងជិតផ្សារកាណាស៊ីធីបានលុយ ចំនួន៥០ (ហាសិបដុល្លារអាមេរិក) ហើយខ្លួនទាំង០៣នាក់ ម្នាក់បានលុយចំនួន ១០០.០០០ (ដប់ម៉ឺនរៀល) រួចហើយក៏បែកផ្លូវ ។ រយៈកាលកន្លងមក រូបខ្លួនពុំធ្លាប់ជាប់ពន្ធនាគារនោះទេ ចំណែកគ្រឿងញៀនគឺខ្លួនមិនចេះជក់។ ខ្លួនសំណូមពរ ឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះបានដឹងពីទោសកំហុសដែល

បានប្រព្រឹត្តកន្លងមកនេះហើយ។

-ជនជាប់ចោទឈ្មោះ [redacted] ហេងលាប បានឆ្លើយថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០២ និង ០០ នាទីយប់រំលងអធ្រាត រូបខ្លួន និងបក្ខពួកចំនួន ០៤ នាក់ទៀត ,ឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង ,ឈ្មោះ [redacted] ចំរើន ហៅ អារើន,ឈ្មោះ [redacted] តុលា ហៅតុលា ,ឈ្មោះ [redacted] សុខហេង កំពុងនាំគ្នាឈប់ម៉ូតូចំនួន០២គ្រឿងអង្គុយលេងនៅខាងមុខបុរីហុងឡាយ ផ្លូវចោមចៅ ហៅផ្លូវវេងស្រេង ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ភ្លាមនោះស្រាប់តែមានកម្លាំងសមត្ថកិច្ចនគរបាលជិះម៉ូតូល្បាតមកដល់ ហើយបានធ្វើការត្រួតពិនិត្យ និងឆែកឆេរលើខ្លួនប្រាណរកឃើញក្រាមពណ៌សថ្លា ចំនួន០១កញ្ចប់ចង់តូច នៅលើខ្លួនប្រាណរបស់ឈ្មោះ [redacted] ចំរើន ហៅអារើន ទុកលក់ឱ្យគេ ចំណែកក្រាមពណ៌សថ្លាចំនួន០១កញ្ចប់ចង់តូច និងថ្នាំគ្រាប់ពណ៌ស្លឹកឈើ (ខៀវខ្ចី) ចំនួន ០២ គ្រាប់ ទៀតនៅលើខ្លួន([redacted] តុលា) ហើយរូបខ្លួន និងបក្ខពួក បានឆ្លើយសារភាពថាពួកខ្លួនធ្លាប់ធ្វើសកម្មភាព ឆក់ទូរស័ព្ទដៃ និងកាបូប នៅតាមផ្លូវសាធារណៈកន្លងមកទើបកម្លាំងសមត្ថកិច្ចនគរបាលបានឃាត់រូបខ្លួន និងបក្ខពួក ចំនួន០៤នាក់ទៀត ,ឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង ,ឈ្មោះ [redacted] ចំរើន ហៅ អារើន ,ឈ្មោះ [redacted] តុលា ហៅតុលា, ឈ្មោះ [redacted] សុខហេង ហៅវ៉ា រួមនិងវត្ថុតាងនាំយកមកសាកសួរនៅផ្នែកនគរបាលយុត្តិធម៌ នៃអធិការដ្ឋាននគរបាល ខណ្ឌពោធិ៍សែនជ័យតែម្តង។ ហើយកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង២០ និង០០នាទី ឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង ជិះម៉ូតូ០១គ្រឿងម៉ាកហុងដាឌ្រីម C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៣ គ្មានផ្លាកលេខ ដឹកឈ្មោះ [redacted] ចំរើន ហៅ អារើន ចំណែកឈ្មោះ [redacted] តុលា ហៅតុលា បានជិះម៉ូតូ០១គ្រឿងម៉ាកហុងដាឌ្រីម C125 ពណ៌ក្រហម ស៊េរីឆ្នាំ២០២២ ពាក់ផ្លាកលេខភ្នំពេញ1JM-8711 ដឹករូបខ្លួន និងឈ្មោះ [redacted] សុខហេង ហៅវ៉ា ដឹកគ្នាចេញទៅដើររកធ្វើសកម្មភាពឆក់ រហូតមកដល់ចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ ក៏ឃើញជនរងគ្រោះ ភេទប្រុសជិះម៉ូតូ០១គ្រឿងម៉ាកហុងដា ស្កុបពីពណ៌ខ្មៅ មិនចាំស៊េរី និងផ្លាកលេខជិះតែម្នាក់ ឯងបានដាក់ទូរស័ព្ទ ដៃ០១គ្រឿង នៅក្នុងហោប៉ៅអាវខាងមុខឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង ក៏ជិះម៉ូតូដឹករូបខ្លួនទៅក្បែរនិងម៉ូតូរបស់ជនរងគ្រោះ រួចឈ្មោះ [redacted] ចំរើន ហៅអារើន បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃពីជនរងគ្រោះ បានសម្រេច ហើយរូបខ្លួន និងបក្ខពួកបាននាំគ្នាជិះម៉ូតូគេចខ្លួន ចេញពីកន្លែងកើតហេតុដោយឈ្មោះ [redacted] ចំរើន ហៅអារើន និងឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង បាននាំគ្នាយកទូរស័ព្ទដៃ០១គ្រឿងម៉ាកOPPO ដែលឆក់បាននោះទៅលក់ នៅហាងទិញលក់ និងបញ្ចាំទូរស័ព្ទដៃ នៅហាងម៉ែអាតាយ ផ្លូវចោមចៅហៅផ្លូវវេងស្រេង ជិតផ្សារកាណាស៊ីធី បានលុយ ចំនួន៥០(ហាសិបដុល្លារអាមេរិក) ហើយខ្លួនទាំង០៣ នាក់ ម្នាក់បានលុយចំនួន២០.០០០៛(ពីរម៉ឺនរៀល) រួចហើយក៏បែកផ្លូវ។ រយៈកាលកន្លងមក រូបខ្លួនពុំធ្លាប់ជាប់ពន្ធនាគារនោះទេ ចំណែកគ្រឿងញៀនគឺខ្លួនចេះជក់។

-ជនជាប់ចោទឈ្មោះ [redacted] សុខហេង បានឆ្លើយថា៖ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០២ និង ០០ នាទីយប់រំលងអធ្រាត រូបខ្លួន និងបក្ខពួកចំនួន០៤នាក់ទៀត ,ឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង ,ឈ្មោះ [redacted] ចំរើន ហៅ អារើន, ឈ្មោះ [redacted] តុលា ហៅតុលា ,ឈ្មោះ [redacted] ហេងលាប ហៅ កែ កំពុងនាំគ្នាឈប់ម៉ូតូចំនួន ០២គ្រឿង អង្គុយលេង នៅខាងមុខបុរីហុងឡាយផ្លូវចោមចៅ ហៅផ្លូវវេងស្រេង ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ភ្លាមនោះស្រាប់តែមានកម្លាំងសមត្ថកិច្ចនគរបាលជិះម៉ូតូល្បាត មកដល់ហើយបានធ្វើការត្រួតពិនិត្យ

និងឆែកឆេរលើខ្លួនប្រាណ រកឃើញក្រាមពណ៌សថ្លា ចំនួន ០១កញ្ចប់ថង់តូច នៅលើខ្លួនប្រាណរបស់ឈ្មោះ[redacted]ចំរើន ហៅអារើន ទុកលក់ឱ្យគេចំណែកក្រាមពណ៌សថ្លាចំនួន០១ កញ្ចប់ថង់តូច និងថ្នាំគ្រាប់ពណ៌ស្លឹកឈើ(ខៀវខ្ចី) ចំនួន ០២ គ្រាប់ ទៀតនៅលើខ្លួនឈ្មោះ [redacted] តុលា ហើយរូបខ្លួន និងបក្ខពួកបានឆ្លើយសារភាពថាពួកខ្លួនធ្លាប់ធ្វើសកម្មភាពឆក់ទូរស័ព្ទដៃ និងកាប្លបនៅតាមផ្លូវសាធារណៈកន្លងមកទើបកម្លាំងសមត្ថកិច្ចនគរបាលបានឃាត់រូបខ្លួន និងបក្ខពួកចំនួន០៤នាក់ទៀត ,ឈ្មោះ[redacted] ម៉េងឡុង ហៅរ៉ុង ,ឈ្មោះ[redacted] ចំរើន ហៅ អារើន ,ឈ្មោះ [redacted] តុលា ហៅតុលា, ឈ្មោះ[redacted] ហេងលាប ហៅកែ រួមនិងវត្ថុតាងនាំយកមកសាកសួរនៅផ្នែកនគរបាលយុត្តិធម៌នៃអធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យតែម្តង។ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង២០ និង០០នាទី ឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង ជិះម៉ូតូ០១គ្រឿង ម៉ាកហុងដាឌ្រីម C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៣ គ្មានផ្លាកលេខ ឌឹកឈ្មោះ[redacted] ចំរើន ហៅអារើន ចំណែក ឈ្មោះ [redacted] តុលា ហៅតុលា បានជិះម៉ូតូ០១គ្រឿងម៉ាកហុងដាឌ្រីម C125 ពណ៌ក្រហម ស៊េរីឆ្នាំ២០២២ ពាក់ផ្លាកលេខភ្នំពេញ 1JM-8711 ឌឹករូបខ្លួន និងឈ្មោះ [redacted] ហេងលាប ហៅកែ ដឹកគ្នាចេញទៅដើររកធ្វើសកម្មភាពឆក់ រហូតមកដល់ចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យក៏ឃើញជនរងគ្រោះ ជិះម៉ូតូ០១គ្រឿងម៉ាកហុងដា ស្កុបពីពណ៌ខ្មៅ មិនចាំស៊េរី និងផ្លាកលេខ ជិះតែម្នាក់ឯងបានដាក់ទូរស័ព្ទដៃ០១គ្រឿង នៅក្នុងហោប៉ៅអាវខាងមុខឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង ក៏ជិះម៉ូតូឌឹករូបខ្លួនទៅក្បែរនិងម៉ូតូរបស់ជនរងគ្រោះ រួចឈ្មោះ[redacted] ចំរើន ហៅអារើន បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃ ពីជនរងគ្រោះបានសម្រេច ហើយរូបខ្លួន និងបក្ខពួក បាននាំគ្នាជិះម៉ូតូគេចខ្លួនចេញពីកន្លែង នឹងឈ្មោះ បានកើតហេតុដោយឈ្មោះ [redacted] ចំរើន ហៅអារើន និងឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង បាននាំគ្នាយកទូរស័ព្ទដៃ ០១គ្រឿងម៉ាកOPPO ដែលឆក់បាននោះទៅលក់នៅហាងទិញលក់និងបញ្ចាំ ទូរស័ព្ទដៃនៅហាងម៉ែអាតាយផ្លូវចោមចៅហៅផ្លូវវេងស្រេងជិតផ្សារកាណាស៊ីធីបានលុយចំនួន៥០(ហាសិបដុល្លារអាមេរិក) ហើយខ្លួនបានលុយចំនួន ៦០.០០០ (ប្រាំមួយម៉ឺនរៀល) រួចហើយក៏បែកផ្លូវគ្នា ។ រយៈកាលកន្លងមករូបខ្លួនពុំធ្លាប់ជាប់ពន្ធនាគារនោះទេ ចំណែកគ្រឿងញៀនគឺខ្លួនចេះជក់។ ខ្លួនសំណូមពរឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះខ្លួនបានដឹងពីទោសកំហុសដែលបានប្រព្រឹត្តនេះហើយ។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១២០៧ រ.វ.ត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដូចខាងក្រោម៖

១.ស្រោមសំបុត្របិទជិតចំនួន ០១ សរសេរថា ក្រាមពណ៌សថ្លាចេញព៌ណលឿងទុំ សង្ស័យថាមានតម្រុយជាសារធាតុញៀនប្រភេទមេតំហ្វេតាមីនទម្ងន់ ០,១១(សូន្យក្បៀសដប់មួយក្រាម)និងសំបកថង់ប្លាស្ទិចចំនួន ០១ ដោយមានស្នាមមេដៃឈ្មោះ អ៊ីន ចំរើន និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌។

២.ស្រោមសំបុត្របិទជិតចំនួន ០១ សរសេរថា ក្រាមពណ៌សថ្លាចេញព៌ណលឿងទុំ សង្ស័យថាមានតម្រុយជាសារធាតុញៀនប្រភេទមេតំហ្វេតាមីនទម្ងន់ ០,៤៨ (សូន្យក្បៀសសែសិបប្រាំបីក្រាម) និងសំបកថង់ប្លាស្ទិចចំនួន០១ ដោយ, ថ្នាំគ្រាប់ពណ៌ស្លឹកឈើចេញពណ៌លឿងប្រផេះសង្ស័យថាមានតម្រុយជាសារធាតុញៀន ប្រភេទអ៊ិចស្តាស៊ី (MDMA) ទម្ងន់ ០,៦៩ (សូន្យក្បៀសហុកសិបប្រាំបួនក្រាម) ដោយមានស្នាមមេដៃឈ្មោះ ង៉ែត តុលា និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌។

## សេចក្តីសន្និដ្ឋានផ្តឹងសុំរបស់តំណាងអយ្យការ

ឆ្លងតាមអង្គសវនាការនេះឃើញថា:ជនជាប់ចោទឈ្មោះ [redacted] តុលា ,ជនជាប់ចោទឈ្មោះ [redacted] សុខហេង , ជនជាប់ចោទឈ្មោះ [redacted] ម៉េងឡុង ហៅ រ៉ុង ,ជនជាប់ចោទឈ្មោះ [redacted] ចំរើន និងជនជាប់ចោទឈ្មោះ [redacted] ហេងលាភ បានឆ្លើយសារភាព ពីអំពើដែលខ្លួនបានប្រព្រឹត្តកន្លងមក ដែលចម្លើយសារភាពនេះ គឺមានភាពស៊ីសង្វាក់គ្នាទៅនឹងភស្តុតាង និងចម្លើយរបស់ជនជាប់ចោទដែលធ្លាប់បានឆ្លើយនៅគ្រប់ដំណាក់កាលនៃនីតិវិធី ហេតុនេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៨១៧ អ.យ.ធ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ ទុកនៅដដែល។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខហេង ,ជនជាប់ចោទឈ្មោះ [redacted] ម៉េងឡុង ហៅ រ៉ុង ,ជនជាប់ចោទឈ្មោះ [redacted] ចំរើន និងជនជាប់ចោទឈ្មោះ [redacted] ហេងលាភ ខ្លួនសូមធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមអង្គសវនាការឃើញថាកូនក្តីខ្លួន បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានធ្វើសកម្មភាព ឆក់កាបូបរបស់ជនរងគ្រោះបានសម្រេចពិតប្រាកដមែន ។ ដោយសារតែកូនក្តីខ្លួនមានការភ្ញាក់រលឹក និងដឹងពីទោសកំហុសដែលខ្លួនបានប្រព្រឹត្តកន្លងមក ក្រោយពេលជាប់ពន្ធនាគារមួយរយៈ កូនក្តីខ្លួនបានពិចារណាកំហុសដែលបានធ្វើនោះហើយ ព្រមទាំងសោកស្តាយអំពើដែលបានធ្វើទាំងនោះយ៉ាងខ្លាំង ម្យ៉ាងវិញទៀត កូនក្តីរបស់ខ្លួនជាអនីតិជន មានការយល់ដឹងតិចតួច ខ្វះការពិចារណា ហើយមិនបានរៀនសូត្រជ្រៅជ្រះ ព្រមទាំងបានសន្យាថា ឈប់ប្រព្រឹត្តអំពើដែលខុសច្បាប់ទៀតហើយ ដូច្នេះ ហើយក្នុងនាមខ្លួន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្លួនសំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយក្តីអនុគ្រោះផង។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] តុលា ខ្លួនសូមធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមអង្គសវនាការឃើញថាកូនក្តីខ្លួន បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានធ្វើសកម្មភាពឆក់កាបូប របស់ជនរងគ្រោះបានសម្រេចពិតប្រាកដមែន។ ដោយសារតែកូនក្តីខ្លួនមានការភ្ញាក់រលឹក និងដឹងពីទោសកំហុសដែលខ្លួនបានប្រព្រឹត្តកន្លងមក ម្យ៉ាងវិញទៀតកូនក្តីរបស់ខ្លួនជាអនីតិជនមានការយល់ដឹងតិច ខ្វះការពិចារណា ហើយមិនបានរៀនសូត្រជ្រៅជ្រះ ព្រមទាំងបានសន្យាថា ឈប់ប្រព្រឹត្តអំពើដែលខុសច្បាប់ទៀតហើយ ដូច្នេះហើយក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្លួនសំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយក្តីអនុគ្រោះផង។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ម៉េងឡុង ហៅ រ៉ុង បាននិយាយសំដីចុងក្រោយបង្អស់ថា ខ្លួនសូមឱ្យតុលាការជួយបន្ធូ បន្ថយទោសឱ្យខ្លួនផង ព្រោះខ្លួនដឹងកំហុសដែលបានប្រព្រឹត្តនេះហើយ។

-ជនជាប់ចោទឈ្មោះ [redacted] តុលា បាននិយាយសំដីចុងក្រោយបង្អស់ថា សូមឱ្យតុលាការ ជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ព្រោះខ្លួនបានដឹងពីទោសកំហុសដែលបានប្រព្រឹត្តនេះហើយ។

-ជនជាប់ចោទឈ្មោះ [redacted] ហេងលាប បាននិយាយសំដីចុងក្រោយបង្អស់ថា សូមឱ្យតុលាការជួយបន្ធូបន្ថយទោសឱ្យខ្លួនផង ព្រោះខ្លួនបានដឹងពីទោសកំហុសដែលបានប្រព្រឹត្តនេះហើយ។

-ជនជាប់ចោទឈ្មោះ [redacted] សុខហេង បាននិយាយសំដីចុងក្រោយបង្អស់ថា សូមឱ្យតុលាការជួយបន្ធូរបន្ថយ



Scanned with CamScanner

ទោសឱ្យខ្លួនផង ព្រោះខ្លួនបានដឹងពីទោសកំហុសដែលបានប្រព្រឹត្តនេះហើយ។

-ជនជាប់ចោទឈ្មោះ [redacted] ចំរើន បាននិយាយសំដីចុងក្រោយបង្អស់ថា សូមឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ព្រោះខ្លួនបានដឹងពីទោសកំហុសដែលបានប្រព្រឹត្តនេះហើយ។

-ក្រោពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានកំណត់ហេតុទទួលវត្ថុចាប់យក

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## **សំអាងហេតុ**

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ៣០៦៧ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២ មកជំនុំជម្រះដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥៤២៧ "ឈ១" ជជ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **ចំរើន** ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ,ជនជាប់ចោទឈ្មោះ [redacted] **តុលា** ភេទប្រុស អាយុ១៧ឆ្នាំជនជាតិខ្មែរ ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវបេតុង វត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ និងនៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌនិងបទ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខបុរីហុងឡាយ ផ្លូវវេងស្រេង ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងជនជាប់ចោទឈ្មោះ [redacted] **ម៉េងឡុង** ហៅ **រ៉ុង** ភេទប្រុស កើតថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៧ ជនជាតិខ្មែរ ,ជនជាប់ចោទឈ្មោះ [redacted] **សុខហេង** ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ និងជនជាប់ចោទឈ្មោះ [redacted] **ហេងលាប** ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ ទៅជំនុំជម្រះពីបទ **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវបេតុង វត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ និងនៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣,មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-និយមន័យមាត្រា ៣៥៣ និយមន័យនៃអំពើលួចអំពើលួចគឺជាអំពើដកហូតដោយទុច្ចរិត នូវទ្រព្យសម្បត្តិ ឬ



Scanned with CamScanner

វត្ថុផ្សេងៗ ទៀតរបស់អ្នកដទៃតាមគ្រប់មធ្យោបាយក្នុងគោលបំណង យកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

**-និយមន័យមាត្រា ៣៥៧ ទោសដែលត្រូវអនុវត្តអំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ១០ (ដប់) ឆ្នាំ ក្នុងករណីដូចតទៅ៖**

1.អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សា។

2.អំពើលួចនេះ ប្រព្រឹត្តឡើងដោយការកាប់គាស់ទម្លុះទម្លាយ។

**-និយមន័យមាត្រា៤០៖** ការកាន់កាប់ ការលាក់ទុក និងសកម្មភាពប្រហាក់ប្រហែលផ្សេងទៀតដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។ ការបញ្ជូនតាមគ្រប់រូបភាពដែលនាំអោយមានការផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬ ពីប្រទេសមួយទៅប្រទេសមួយទៀតដោយខុសច្បាប់នូវសារធាតុញៀន ជាអាទិ៍តាមរយៈការផ្ញើ ការធ្វើចរាចរណ៍ ការនាំចូលឬការនាំចេញ គឺជាអំពើដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ។ ការផ្តល់សម្រាប់លក់ការលក់ ការទិញដើម្បីលក់ ឬ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ បទរក្សាទុក ដឹកជញ្ជូនឬជួញដូរដោយខុសច្បាប់ដោយសារធាតុញៀនដែលស្ថិតនៅតារាងទី១ និងតារាងទី២ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំទៅ៥ (ប្រាំ)ឆ្នាំ។ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួល បន្ថែមនូវទោសពិន័យជាប្រាក់ពី ៤,០០០,០០០៛ (បួនលានរៀល) ទៅ ១០,០០០,០០០៛ (ដប់លានរៀល) ។

**-និយមន័យមាត្រា៤៥៖** ជនណាប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ក្នុងតារាងទី១ និងតារាងទី២ តាមគ្រប់រូបភាព និងធ្លាប់ត្រូវ បានទទួលរងនូវវិធានការព្យាបាលដោយបង្ខំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦(ប្រាំមួយ)ខែ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០០,០០០៛ (មួយសែនរៀល) ទៅ ១,០០០,០០០៛ (មួយលានរៀល) ។

**២-តាមដីកាសន្និដ្ឋានស្ពាពរលេខ ៣៨១៧ អ.យ.ព ចុះថ្ងៃទី០៦ខែតុលា ឆ្នាំ២០២២** របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញបានបញ្ជាក់ថា កាលពីថ្ងៃទី២០ និងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ពិតជាមានករណី **លួចមានស្ថានទម្ងន់ទោស រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ ,ជនជាប់ចោទឈ្មោះ [redacted] តុលា ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ចំពោះ ជនជាប់ចោទឈ្មោះ [redacted] ម៉េងឡុង ហៅ វ៉ុង ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ,ជនជាប់ចោទឈ្មោះ ហៃ សុខហេង ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ និងជនជាប់ចោទឈ្មោះ [redacted] ហេងណាប ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ ពិតជាបានធ្វើសកម្មភាពឆក់យកកាបូបនិងទូរស័ព្ទដៃពីជនរងគ្រោះដែលកំពុងធ្វើដំណើរ នៅចំណុចតាមបណ្តោយ ផ្លូវបេតុង វត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ និងនៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍-សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ពិតប្រាកដមែន។

៣-តាមចម្លើយរបស់ជនជាប់ចោទទាំង ០៥ នាក់ ដែលបានឆ្លើយនាពេលសវនាការ តុលាការពិចារណាឃើញ



Scanned with CamScanner

ថា៖ ជនជាប់ចោទទាំងអស់ បានឆ្លើយសារភាពពីទង្វើដែលខ្លួនបានប្រព្រឹត្តគឺករណី លួច មានស្ថានទម្ងន់ទោស រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលអំពើប្រព្រឹត្តនេះគឺមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ដែលបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា ជនជាប់ចោទទាំង ០៥ នាក់ ពិតជាបានធ្វើសកម្មភាព ឆក់ទូរស័ព្ទ របស់ជនរងគ្រោះ នៅវេលាម៉ោង ០៥ និង ៤០ នាទីព្រឹក នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ នៅខាងកើតវត្តអង្គតាមិញ ភូមិគោកចំបក សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ និងថ្ងៃដដែល វេលាម៉ោង០៦ និង ១៥ នាទី ស្ថិតនៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ បានសម្រេចពិតប្រាកដមែន។ អំពើ និងសកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទទាំង ០៥ នាក់ ខាងលើនេះ គឺជាបទល្មើសព្រហ្មទណ្ឌដែលច្បាប់បានចែង និងតម្រូវឱ្យផ្តន្ទាទោស។

៤-តំណាងអយ្យការប្តឹងសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៨១៧ អ.យ.ធចុះថ្ងៃទី០៦ ខែតុលាឆ្នាំ២០២២ទុកជាបានការដដែល និងសូមឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ ដែលចំណុចនេះគប្បីតុលាការពិចារណា សម្រេចតាមព្យសនកម្ម និងអង្គហេតុដែលបានកើតឡើងជាក់ស្តែង ។

៥-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខហេង ,ជនជាប់ចោទឈ្មោះ [redacted] ម៉េងឡុង ហៅ រ៉ុង ,ជនជាប់ចោទឈ្មោះ [redacted] ចំរើន និងជនជាប់ចោទឈ្មោះ [redacted] ហេងលាភ ខ្លួនសូមធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមអង្គសវនាការឃើញថាកូនក្តីខ្លួន បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានធ្វើ សកម្មភាពឆក់កាបូបរបស់ជនរងគ្រោះបានសម្រេចពិតប្រាដមែន។ ដោយសារតែកូនក្តីខ្លួនមានការភ្ញាក់រលឹក និងដឹងពីទោសកំហុសដែលខ្លួនបានប្រព្រឹត្តកន្លងមក ក្រោយពេលជាប់ពន្ធនាគារមួយរយៈ កូនក្តីខ្លួនបានពិចារណាកំហុសដែលបានធ្វើនោះហើយព្រមទាំងសោកស្តាយអំពើដែលបានធ្វើទាំងនោះយ៉ាងខ្លាំង ម្យ៉ាងវិញទៀតកូនក្តីរបស់ខ្លួនជាអនីតិជន មានការយល់ដឹងតិចតួច ខ្វះការពិចារណា ហើយមិនបានរៀនសូត្រជ្រៅជ្រះ ព្រមទាំងបានសន្យាថា ឈប់ប្រព្រឹត្តអំពើដែលខុសច្បាប់ទៀតហើយ ដូច្នេះហើយក្នុងនាមខ្លួន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្លួនសំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយក្តីអនុគ្រោះផង ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] តុលា ខ្លួនសូមធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមអង្គសវនាការឃើញថាកូនក្តីខ្លួន បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានធ្វើសកម្មភាពឆក់កាបូប របស់ជនរងគ្រោះបានសម្រេចពិតប្រាដមែន ។ ដោយសារតែកូនក្តីខ្លួនមានការភ្ញាក់រលឹក និងដឹងពីទោសកំហុសដែលខ្លួនបានប្រព្រឹត្តកន្លងមក ម្យ៉ាងវិញទៀតកូនក្តីរបស់ខ្លួនជាអនីតិជនមានការយល់ដឹងតិច ខ្វះការពិចារណា ហើយមិនបានរៀនសូត្រជ្រៅជ្រះ ព្រមទាំងបានសន្យាថា ឈប់ប្រព្រឹត្តអំពើដែលខុសច្បាប់ទៀតហើយ ដូច្នេះហើយក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្លួនសំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយក្តីអនុគ្រោះផង។

ចំពោះការស្នើសុំរបស់មេធាវីទាំងពីរនេះ គប្បីតុលាការ និងលើកយកមកធ្វើការពិចារណាទៅតាមអត្តចរិតការភ្ញាក់រលឹក ការដឹងពីកំហុស របស់ជនជាប់ចោទ។

៦-ជនជាប់ចោទឈ្មោះ [redacted] ចំរើន, ឈ្មោះ [redacted] តុលា ឈ្មោះ [redacted] ម៉េងឡុង ហៅ រ៉ុង, ឈ្មោះ [redacted] សុខហេង និងជនជាប់ចោទឈ្មោះ [redacted] ហេងលាប បាននិយាយសំដីចុងក្រោយប្រហាក់ប្រហែលគ្នាថាសុំឱ្យតុលាការជួយបន្ធូរ



Scanned with CamScanner

បន្ថយទោសផង ព្រោះពួកខ្លួនបានដឹងពីទោសកំហុសដែលបានប្រព្រឹត្តកន្លងមកនេះហើយ។

ចំពោះការសំណូមពរសំដីចុងក្រោយរបស់ជនជាប់ចោទ គប្បីតុលាការធ្វើការពិចារណា ដោយផ្អែកទៅលើការភ្ញាក់រលឹកដឹងពីទោសកំហុសរបស់ជនជាប់ចោទទាំងអស់។

៧-ជនជាប់ចោទឈ្មោះ [redacted] ចំរើន និងជនជាប់ចោទឈ្មោះ [redacted] តុលា បានប្រព្រឹត្តអំពើទុច្ចរិត **លួចមានស្ថានទម្ងន់ទោស** និងបទ **រក្សាទុក និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដែលបានបំពានទៅនិងនីត្យានុកូលភាពនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងក្នុងបញ្ញត្តិមាត្រា៣៥៣, មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤០, មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-ជនជាប់ចោទឈ្មោះ [redacted] **ម៉េងឡុង** ហៅ វ៉ុង ,ជនជាប់ចោទឈ្មោះ [redacted] **សុខហេង** និងជនជាប់ចោទឈ្មោះ [redacted] **ហេងលាប** បានប្រព្រឹត្តអំពើទុច្ចរិត **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដែលបានបំពានទៅនិងនីត្យានុកូលភាពនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងក្នុងបញ្ញត្តិមាត្រា៣៥៣ ,មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩-អំពើ និង សកម្មភាពរបស់ជនជាប់ចោទធ្វើអោយខូចសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់បុគ្គលឯកជនដែលច្បាប់បានការពារ និងតម្រូវឱ្យផ្តន្ទាទោស។

១០-ពេលធ្វើសកម្មភាពជនជាប់ចោទមានសតិបញ្ញាស្មារតីគ្រប់គ្រាន់ ប្រព្រឹត្តអំពើល្មើសច្បាប់រហូតសម្រេចតាមបំណងរបស់ខ្លួន។

១១-ជនជាប់ចោទទាំងប្រាំនាក់ ជាអនីតិជន តាមបញ្ញត្តិមាត្រា១៦០ (មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅ) នៃក្រមព្រហ្មទណ្ឌ បានចែងថា "កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅមូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដែលអតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ហេតុដូច្នេះគប្បីតុលាការពិចារណាតាមច្បាប់។

**១២-វត្ថុចាប់យកដែលត្រូវរឹបអូសរួមមានដូចខាងក្រោម៖**

ក.ស្រោមសំបុត្របិទជិតចំនួន ០១ សរសេរថា ក្រាមពណ៌សថ្លាចេញព័ណលឿងទុំ សង្ស័យថាមានតម្រុយជាសារធាតុញៀនប្រភេទមេតំហ្វេតាមីនទម្ងន់ ០,១១ (សូន្យក្បៀសដប់មួយក្រាម) និងសំបកថង់ប្លាស្ទិចចំនួន ០១ ដោយមានស្លាមមេដៃឈ្មោះ [redacted] ចំរើន និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌។

ខ.ស្រោមសំបុត្របិទជិតចំនួន ០១ សរសេរថា ក្រាមពណ៌សថ្លាចេញព័ណលឿងទុំ សង្ស័យថាមានតម្រុយជាសារធាតុញៀនប្រភេទមេតំហ្វេតាមីនទម្ងន់ ០,៤៨ (សូន្យក្បៀសសែសិបប្រាំបីក្រាម) និងសំបកថង់ប្លាស្ទិចចំនួន០១ ដោយ ,ថ្នាំគ្រាប់ពណ៌ស្វ៉ាកឈើចេញពណ៌លឿងប្រផេះសង្ស័យថាមានតម្រុយជាសារធាតុញៀន ប្រភេទអ៊ិចស្តាស៊ី (MDMA) ទម្ងន់ ០,៦៩ (សូន្យក្បៀសហុកសិបប្រាំបួនក្រាម) ដោយមានស្លាមមេដៃឈ្មោះ [redacted] តុលា និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌។

១៣-នៅពេលប្រព្រឹត្តបទជនជាប់ចោទទាំងប្រាំនាក់ជា អនីតិជន មានកាលយល់ដឹងតិច ហើយទើបតែបានប្រព្រឹត្តបទល្មើសជាលើកទីមួយ គប្បីតុលាការពិចារណាអំពីការព្យួរទោសលើជនជាប់ចោទ ដោយអនុលោមទៅតាមបញ្ញត្តិមាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

១៤-មានពិរុទ្ធភាពនិងភស្តុតាងគ្រប់គ្រាន់លើឈ្មោះ [redacted] **ចំរើន** ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ, ជនជាប់-

ចោទឈ្មោះ [redacted] តុលា ភេទប្រុស អាយុ១៧ឆ្នាំជនជាតិខ្មែរ ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវបេតុង វត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ និងនៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌនិងបទ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខបុរីហុងឡាយ ផ្លូវវេងស្រេង ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍-សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **៤០** និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ព្រមទាំងមានពិរុទ្ធភាពនិងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ម៉េងឡុង** ហៅ **រ៉ុង** ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ ,ជនជាប់ចោទឈ្មោះ [redacted] **សុខហេង** ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ និងជនជាប់ចោទឈ្មោះ [redacted] **ហេងលាប** ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ ពីបទ **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវបេតុង វត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ និងនៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣,មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោសលើជនជាប់ចោទ

ក.ឈ្មោះ [redacted] **ចំរើន**ភេទប្រុសអាយុ១៥ឆ្នាំជនជាតិខ្មែរ

ខ.ឈ្មោះ [redacted] **តុលា**ភេទប្រុស អាយុ១៧ឆ្នាំជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន **១៨ខែ (ដប់ប្រាំបីខែ)** តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់ចំនួន **១០ខែ (ដប់ខែ)** ទោសដែលនៅសល់ត្រូវព្យួរធម្មតា ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវបេតុង វត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ និងនៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងបទ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខបុរីហុងឡាយ ផ្លូវវេងស្រេង ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននិងមាត្រា១៦០, មាត្រា១០៧, មាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

គ.ឈ្មោះ [redacted] **ម៉េងឡុង** ហៅ **រ៉ុង** ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ

ឃ.ឈ្មោះ [redacted] **សុខហេង** ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ



Scanned with CamScanner

ង.ឈ្មោះ [redacted] **ហេងណាប** ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន **១៨ខែ (ដប់ប្រាំបីខែ)** តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់ចំនួន ១០ខែ (ដប់ខែ) ទោសដែលនៅសល់ត្រូវព្យួរធម្មតាពីបទ **លួចមានស្ថានទម្ងន់ទោស និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវបេតុង វត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ និង នៅចំណុចផ្លូវ៣០ម៉ែត្រ ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា**៣៥៣**,មាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ, មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា**១៦០**, មាត្រា**១០៧**, មាត្រា**១០៨** នៃក្រមព្រហ្មទណ្ឌ។

**ខ-វត្ថុចាប់យកដែលត្រូវរឹបអូសរួមមាន៖** ស្រោមសំបុត្របិទជិតចំនួន ០១ សរសេរថា ក្រោមពណ៌សថ្លាចេញពណ៌លឿងទុំ សង្ស័យថាមានតម្រុយជាសារធាតុញៀនប្រភេទមេតំហ្វេតាមីនទម្ងន់ 0,១១ (សូន្យក្បៀសដប់មួយក្រាម និងសំបកថង់ប្លាស្ទិចចំនួន ០១ ដោយមានស្នាមមេដៃឈ្មោះ អ៊ុន ចំរើន ,ស្រោមសំបុត្របិទជិតចំនួន០១ សរសេរថា ក្រោមពណ៌សថ្លាចេញពណ៌លឿងទុំ សង្ស័យថាមានតម្រុយជាសារធាតុញៀនប្រភេទ មេតំហ្វេតាមីនទម្ងន់ 0,៤៨ (សូន្យក្បៀសសែសិបប្រាំបីក្រាម) និងសំបកថង់ប្លាស្ទិចចំនួន ០១, ថ្នាំគ្រាប់ពណ៌ស្លែកឈើចេញពណ៌លឿងប្រផេះ សង្ស័យថាមានតម្រុយជាសារធាតុញៀន ប្រភេទអ៊ិចស្តាស៊ី (MDMA) ទម្ងន់ 0,៦៩ (សូន្យក្បៀសហុកសិបប្រាំបួនក្រាម) ដោយមានស្នាមមេដៃឈ្មោះ [redacted] តុលា និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចំរើន, ឈ្មោះ [redacted] តុលា, ឈ្មោះ [redacted] ម៉េងឡុង ហៅរ៉ុង, ឈ្មោះ [redacted] សុខហេង ,និងចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហេងណាប, ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៣រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

**បានឃើញ**

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ក្រឡាបញ្ជី**

[redacted]

[redacted]